ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ២២/១៣-ក្បាលកោះ
កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ ៖ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៣

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ទូន ស៊ីផាន់**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ក្បាលកោះ ហ្គាមេន ខូអិលធីឌី**

អាសយដ្ឋាន ៖ ផ្លូវជាតិលេខ ១ ភូមិជ្រោយអំពិល សង្កាត់ក្បាលកោះ ខណ្ឌមានជ័យ ក្រុងភ្នំពេញ

ទូរស័ព្ទ ៖ ០១៧ ៩៨៥ ០៦៨ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

- លោក ឃិន វ៉ាន់ រដ្ឋបាល

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ - **សហព័ន្ធសហជីពជាតិកម្មករកម្ពុជា**

- **សហជីពជាតិកម្មករកម្ពុជាប្រចាំក្រុមហ៊ុន ក្បាលកោះ**

អាសយដ្ឋាន ៖ ផ្លូវជាតិលេខ ១ ភូមិជ្រោយអំពិល សង្កាត់ក្បាលកោះ ខណ្ឌមានជ័យ ក្រុងភ្នំពេញ

ទូរស័ព្ទ ៖ ០១៧ ៨៥៥ ៥៣៦ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

១-លោក គុល ផាន់មឿង ប្រធានសហព័ន្ធសហជីពជាតិកម្មករកម្ពុជា

២-លោក ប៊ុន សុរម្យ ប្រធានសហជីពជាតិកម្មករកម្ពុជាប្រចាំក្រុមហ៊ុន

៣-លោក ឡៃ ចំរើន អនុប្រធានសហជីពជាតិកម្មករកម្ពុជាប្រចាំក្រុមហ៊ុន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១-ថ្នាក់ដឹកនាំសហជីពជាតិកម្មករកម្ពុជាប្រចាំក្រុមហ៊ុន នៅតែទាមទារឱ្យក្រុមហ៊ុនរៀបចំឱ្យមានលុយបាយថ្ងៃត្រង់១ ថ្ងៃ ចំនួន ២០០០ រៀល ជារៀងរាល់ថ្ងៃ។ ដោយឡែកក្រុមហ៊ុនមិនអាចផ្តល់ជូនតាមការទាមទារបានទេ។

២-ថ្នាក់ដឹកនាំសហជីពជាតិកម្មករកម្ពុជាប្រចាំក្រុមហ៊ុននៅតែទាមទារឱ្យក្រុមហ៊ុនប្តូរកិច្ចសន្យាការងារខ្លី ពី ៣ ខែ ទៅ ១ឆ្នាំ ម្តង។ ដោយឡែកក្រុមហ៊ុនសុំធ្វើការសិក្សាលើករណីនេះសិន។

៣-ថ្នាក់ដឹកនាំសហជីពជាតិកម្មករកម្ពុជាប្រចាំក្រុមហ៊ុននៅតែទាមទារឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួលគោលពីមួយខែ៧០ដុល្លារ ទៅ ១០០ ដុល្លារ។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចតម្លើងជូនបានទេ ក្រុមហ៊ុនផ្តល់ជូនតាមច្បាប់កំណត់។

៤-ថ្នាក់ដឹកនាំសហជីពជាតិកម្មករកម្ពុជាប្រចាំក្រុមហ៊ុនទាមទារឱ្យក្រុមហ៊ុនរៀបចំឱ្យមានលុយបាយ ពេលធ្វើការថ្ងៃបុណ្យ និងថ្ងៃអាទិត្យចំនួន ២០០០រៀលក្នុងមួយថ្ងៃ។ ដោយឡែកក្រុមហ៊ុនបញ្ជាក់ថា សុំសិក្សាលើច្បាប់សិន។

៥-ថ្នាក់ដឹកនាំសហជីពជាតិកម្មករកម្ពុជាប្រចាំក្រុមហ៊ុនទាមទារឱ្យក្រុមហ៊ុនគិតប្រាក់បំណាច់កិច្ចសន្យា ចំពោះកម្មករដែលធ្វើការច្រើនឆ្នាំ។ ដោយឡែកក្រុមហ៊ុនមិនអាចធ្វើទៅតាមការទាមទារបានទេ។

៦-ថ្នាក់ដឹកនាំសហជីពជាតិកម្មករកម្ពុជាប្រចាំក្រុមហ៊ុនទាមទារចំពោះកម្មករនិយោជិតឈប់ ដោយគ្មានច្បាប់អនុញ្ញាតមួយថ្ងៃ សុំឱ្យក្រុមហ៊ុនកាត់ប្រាក់រង្វាន់ធ្វការទៀងទាត់ចំនួន ៥ ដុល្លារ។ ដោយឡែកក្រុមហ៊ុនបញ្ជាក់ថាករណីកម្មករឈប់មានច្បាប់អនុញ្ញាតត្រឹមត្រូវមួយថ្ងៃ ក្រុមហ៊ុនកាត់ប្រាក់រង្វាន់ការងារទៀងទាត់ចំនួន៥ដុល្លារ។

៧-ថ្នាក់ដឹកនាំសហជីពជាតិកម្មករកម្ពុជាប្រចាំក្រុមហ៊ុនទាមទារឱ្យក្រុមហ៊ុនរៀបចំឱ្យមានប្រាក់រង្វាន់ដល់ជំនួយការគ្រប់ក្រុម គ្រប់ផ្នែក។ ដោយឡែកក្រុមហ៊ុនមិនអាចផ្តល់ជូនបានទេ។

៨-ថ្នាក់ដឹកនាំសហជីពជាតិកម្មករកម្ពុជាប្រចាំក្រុមហ៊ុនទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករមុខងារដូរម្ជុល។ ដោយឡែកក្រុមហ៊ុនមិនអាចផ្តល់ជូនទៅតាមការទាមទារបានទេ។

៩-ថ្នាក់ដឹកនាំសហជីពជាតិកម្មករកម្ពុជាប្រចាំក្រុមហ៊ុនទាមទារឱ្យក្រុមហ៊ុនរៀបចំឱ្យមានប្រាក់រង្វាន់សម្រាប់ក្រុមតុកាត់។ ដោយឡែកក្រុមហ៊ុនមិនអាចផ្តល់ជូនទៅតាមការទាមទារបានទេ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១២១ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ (អាណត្តិទី១០)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ

ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១១៦ កប/អក/វក ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣។

**សវនាការ និង សង្ខេបនីតិវិធី**

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទជួបប្រជុំមុនសវនាការ ៖** ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៣ (វេលាម៉ោង ០៤ និង ០០ នាទី រសៀល )។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹង ស្តីពីកម្មករនិយោជិតធ្វើកូដកម្មទាមទារឱ្យក្រុមហ៊ុនកែលម្អល័ក្ខខ័ណ្ឌការងារឱ្យបានល្អប្រសើរ។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះ ជាបន្តបន្ទាប់ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០៩ ចំណុច លើការទាមទារចំនួន ១២ ចំណុច។

ចំណុចមិនសះជាចំនួន ០៩ចំណុច ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១៣ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម លេខ ១១៦ ក.ប/អក/វក ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣។

ដោយសារតែកម្មករនិយោជិតបានធ្វើកូដកម្ម ចាប់តាំងពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣ ហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលដំណឹងពីភាគីទាំងពីរថា កូដកម្មនៅតែបន្តនៅក្រុមហ៊ុន ក្បាលកោះ ហ្គាមេន ដដែល ទោះបីជាសំណុំរឿងត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ដោយ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចចេញសេចក្តីបញ្ជា លេខ ០០៣/១៣ កបអ. ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣ ឱ្យកូដករផ្អាកជាបន្ទាន់នូវការធ្វើកូដកម្មនៅក្រុមហ៊ុន ក្បាលកោះ ហ្គាមេន រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាល ត្រូវបានចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីរសៀលថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ តទៅ តាមវេនរបស់ខ្លួន។ ប៉ុន្តែ ទោះបីជាមានសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលឱ្យកូដករទាំងអស់បញ្ឈប់ធ្វើកូដកម្ម និងត្រឡប់ចូលធ្វើការវិញក៏ដោយ ក៏កូដកម្មនៅតែបន្តនៅក្រុមហ៊ុន ក្បាលកោះ ហ្គាមេន ដដែល។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីទាំងពីរ មកបំភ្លឺនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ វេលាម៉ោង ៤ រសៀល ដើម្បីបញ្ជាក់អំពីជំហរចុងក្រោយរបស់ភាគីកម្មករនិយោជិតក្នុងការធ្វើកូដកម្ម និងជំហររបស់និយោជកក្នុងការអនុញ្ញាតឱ្យកម្មករនិយោជិតចូលធ្វើការវិញ។

ភាគីទាំងពីរ បានចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល តាមពេលវេលាកំណត់។ ភាគីកម្មករនិយោជិតបានបញ្ជាក់ជំហរថា ចាប់ពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៣តទៅ កូដករដែលជាសមាជិករបស់សហជីពនឹងឈប់ធ្វើកូដកម្ម ហើយត្រឡប់ចូលធ្វើការវិញ។ ភាគីកម្មករនិយោជិតបានអះអាងថា នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៣ ភាគីកម្មករនិយោជិតនឹងជម្រាបជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល អំពីបច្ចុប្បន្នភាពនៃកូដកម្មនេះ។ ប៉ុន្តែ មកដល់ថ្ងៃកំណត់ ភាគីកម្មករនិយោជិតមិនបានផ្តល់ដំណឹងណាមួយ ដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ។

លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមទាក់ទងទៅភាគីកម្មករនិយោជិត។ ប៉ុន្តែ មិនអាចទំនាក់ទំនងបាន។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានទាក់ទងទៅភាគីនិយោជក ហើយទទួលបានព័ត៌មានពីភាគីនិយោជកថា កូដកម្មនៅតែបន្ត ទោះបីជាមានកូដករមួយចំនួនបានត្រឡប់ចូលធ្វើការវិញក៏ដោយ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើចំណុចវិវាទខាងលើនេះ ដូចខាងក្រោម៖

**សវនាការ**

សាក្សី និង អ្នកជំនាញក្រៅពីភាគី៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក៖

- លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣ របស់នាយកក្រុមហ៊ុន ក្បាលកោះ ប្រគល់សិទ្ធិជូនលោក ឃិន វ៉ាន់ ឱ្យធ្វើជាតំណាងក្នុងការដោះស្រាយវិវាទរវាងក្រុមហ៊ុន និងកម្មករ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ក្បាលកោះ លេខ ១១៦ កប/អក/វក ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ក្បាលកោះ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មាន លេខ ០៩៥ កប/អក/វក/លកអ. ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ។

៣- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមផ្តល់ព័ត៌មាន លេខ ០៩៦ កប/អក/វក/លកអ. ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ២០១៣ ។

**អង្គហេតុ**

- មិនមានការរកឃើញអង្គហេតុទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជាដែលនាយកដ្ឋានវិវាទការងារ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានដំណើរការសវនាការ។

**ហេតុផលនៃសេចក្តីសម្រេច÷**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ? ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង

THE ARBITRATION COUNCIL

យុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា ៖ *“ ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀតដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម ”* ។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាភាគីកម្មករនិយោជិតកំពុងធ្វើកូដកម្ម ។

ឧទាហរណ៍ នៅក្នុងសំណុំរឿងលេខ ០៤/០៤-អិម អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីជូនដំណឹងមួយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខ័ណ្ឌទី៤ នៃសេចក្តីជូនដំណឹងនេះ កំណត់ថា ៖

*“ ដោយពិនិត្យឃើញថា ភាគីនៃវិវាទការងារនេះមិនមានសិទ្ធិធ្វើកូដកម្ម ក្នុងកំឡុងពេលនៃដំណើរការរបស់អាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្តីបង្គាប់លើវិវាទការងាររួមនេះបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដោះស្រាយវិវាទការងាររួមនេះម្តងទៀតបាន នៅពេលណាដែលសហជីពកម្មករនិយោជិតទាំងអស់ឈប់ធ្វើកូដកម្ម ”*។

ដូចគ្នាដែរ នៅក្នុងសំណុំរឿងលេខ ១៨/០៤-សណ្ឋាគារ (កាំបូឌីយ៉ាណា, រ៉ាហ្វែល ឡឺរ៉ូយ៉ាល់, រ៉ាហ្វល ប្រែ្រនឌិ អង្គរ, សាន់វេ, អ៊ិនធើខនធីណេនថល និង សូហ្វីតែល អង្គរ) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទីពីរ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៤ ត្រង់ចំណុចទី៩ និងទី១១ នៃសេចក្តីបញ្ជានេះចែងដូចខាងក្រោម ៖

*“ ចំណុចទី៩- ចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ តទៅ កម្មករនិយោជិតទាំងអស់ត្រូវបញ្ឈប់កូដកម្ម បាតុកម្ម ឬ ការរំខានណាមួយ នៅក្នុងបរិវេណសណ្ឋាគារនានា ដែលជាភាគីនៃវិវាទនេះ ”* ។

*“ ចំណុចទី ១១ - ក្រុមប្រឹក្សាអាជ្ញាកណ្តាលរក្សាសិទ្ធិក្នុងការបញ្ចប់ដំណើរការអាជ្ញាកណ្តាល ករណីដែលភាគីណាមួយបំពានប្រការណាមួយនៃសេចក្តីបញ្ជានេះ ”* ។

នៅក្នុងសំណុំរឿងលេខ ៧៧/០៦-ហ្វ្រង់កូ នីតធីង ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទី២ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៥ ហើយបានចែងនៅក្នុងចំណុចទី៤ថា នៅក្នុងករណីដែលភាគីកម្មករនិយោជិតបន្តធ្វើកូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនដំណើរការដោះស្រាយវិវាទការងាររួមនេះទេ ។

នៅក្នុងសំណុំរឿងលេខ ១១០/១១-ស៊ីម៉ាញូ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានចេញសេចក្តីបង្គាប់មិនបន្តដំណើរការអាជ្ញាកណ្តាល ដោយមូលហេតុកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មក្នុងកំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែរ ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ឯកភាពតាមការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងខាងលើដែរ ។

នៅក្នុងករណីនេះ ភាគីកម្មករនិយោជិតបានបញ្ជាក់ជំហរថា ចាប់ពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៣ តទៅ កូដករដែលជាសមាជិករបស់សហជីពនឹងឈប់ធ្វើកូដកម្ម ហើយត្រឡប់ចូលធ្វើការវិញ ។ ភាគីកម្មករនិយោជិតបានអះអាងថា នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៣ ភាគីកម្មករនិយោជិត នឹងជម្រាបជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល អំពី

THE ARBITRATION COUNCIL

បច្ចុប្បន្នភាពនៃកូដកម្មនេះ។ ប៉ុន្តែ មកដល់ថ្ងៃកំណត់ ភាគីកម្មករនិយោជិត មិនបានផ្តល់ដំណឹងណាមួយដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានព្យាយាមទាក់ទងទៅភាគីកម្មករនិយោជិត។ ប៉ុន្តែ មិនអាចទំនាក់ទំនងបាន។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានទាក់ទងទៅភាគីនិយោជក ហើយទទួលបានព័ត៌មានពីភាគីនិយោជកថា កូដកម្មនៅតែបន្ត ទោះបីជាមានកូដករមួយចំនួនបានត្រឡប់ចូលធ្វើការវិញក៏ដោយ។ នៅក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលស្គាល់អំណះអំណាងរបស់ភាគីនិយោជកថា កម្មករនិយោជិតមួយចំនួននៅតែបន្តធ្វើកូដកម្ម រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៣ នេះ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច មិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះទេ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ៖

## សម្រេច និង បង្គាប់

- មិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ២២/១៣- ក្បាលកោះ ហ្គាមេន ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក៖**

ឈ្មោះ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា៖ ------------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត៖**

ឈ្មោះ៖ **ឡូន ស៊ីផាន់**

ហត្ថលេខា៖ ------------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល៖**

ឈ្មោះ៖ **ប៉ែន ម៉ុនឈា**

ហត្ថលេខា៖ ------------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL